ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Nov-2015, 15:27
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល:
ឋានៈនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការកំណត់បទចោទជាសក្ខានុពលឡើងវិញ លើខ្សែក្រិដ្ឋកម្មនានា**

---

ដាក់ដោយ៖
**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

ផ្ញើជូន៖
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរិវឌ្ឍ
ចៅក្រម C.N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

ចម្លងជូន៖
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ៖**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តី**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

## I.សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញា តាមរយៈនេះ ធ្វើការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូល ("អជតក") សុំឲ្យដាក់សេចក្តីសន្និដ្ឋានស្តីពីលទ្ធភាពនៃការប្តូរការកំណត់បទចោទប្រកាន់។

## II.ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយរបស់ខ្លួនលើសំណុំរឿង០០២ ("ដីកាដំណោះស្រាយ") ដោយបានបញ្ជូនទៅជំនុំជម្រះក្តី *ក្នុងចំណោមបុគ្គលទាំងនោះ* មាន នួន ជា និង ខៀវ សំផន[1]។

3. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដែលបានកម្រិតវិសាលភាពនៃសវនាការវគ្គទីមួយនៃសំណុំរឿង០០២ នៅត្រឹមការលើកឡើងចោទប្រកាន់ស្តីពីអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ មានដូចជា ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ និងទីពីរ) ("ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I)" និង "ការផ្លាស់ទីលំនៅ ប្រជាជន (ដំណាក់កាលទី II)") ហើយនិង ឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបាន ប្រព្រឹត្តនៅក្នុងពេលនោះ[2]។ វិសាលភាពនៃសំណុំរឿង០០២/០១ ក្រោយមកត្រូវបានពន្លាត ដោយដាក់បញ្ចូលនូវ ការសម្លាប់អតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ[3]។ នៅថ្ងៃទី ០៨ ខែកុម្ភៈ

---

[1] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០ ("ដីកាដំណោះស្រាយ")។

[2] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១។

[3] **E163/5** សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំង ឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ៨ តុលា ២០១២។ នៅពេលជាមួយគ្នានោះ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងពីឯកសារ **E124/7.3** ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ០០២/០១ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១ (E163), ៨ តុលា ២០១២ ("ឧបសម្ព័ន្ធ") ដោយបានរៀបរាប់ជាបញ្ជីកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ ដែលជាផលវិបាកចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

ឆ្នាំ២០១៣ អជតក បានធ្វើមោឃភាពដីកាសម្រេចបំបែកកិច្ច ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្ដីសម្រេចនានាដែលពាក់ព័ន្ធ[4]។ នៅ ក្រោយការដាក់ជូននានាបន្ថែមទៀតពីសំណាក់ភាគីទាំងឡាយ អង្គជំនុំជម្រះសាលាដំបូង ជាថ្មីម្ដង ទៀត បានបំបែកកិច្ចដំណើរការនីតិវិធី លើសំណុំរឿង០០២ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ដោយបានកម្រិតវិសាលភាពនៃសំណុំរឿង ០០២/០១ នៅត្រឹមឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្ស ជាតិ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃ ដំណើរការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាល ទី I និងដំណាក់កាលទី II) ហើយ និង ការសម្លាប់មន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ[5]។ ជាថ្មីម្ដងទៀត អង្គជំនុំជម្រះសាលាដំបូង បានកំណត់អត្តសញ្ញាណលើកថាខណ្ឌជាក់លាក់នានានៃ ដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[6]។

4. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ នួន ជា និង ខៀវ សំផន បានដាក់សារណារបស់ខ្លួន ទាក់ទងនឹងច្បាប់ដែលអាចអនុវត្តបានចំពោះសំណុំរឿង០០២/០១[7]។ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ពួកគាត់បានដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[8] ហើយនៅចន្លោះថ្ងៃទី១៦ និងទី៣១ ខែតុលា ឆ្នាំ២០១៣ ពួកគាត់បានធ្វើសេចក្ដីថ្លែងបិទ។

---

[4] **E163/5/1/13** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូង ស្ដីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១, ៨ កុម្ភៈ ២០១៣។

[5] **E1/176.1** ប្រតិចារឹក ២៩ មីនា ២០១៣, ទំព័រ២-៤។ **E284** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា២០១៣។

[6] អង្គជំនុំជម្រះសាលាដំបូងបានធ្វើដូច្នេះ ដោយការចេញសារជាថ្មីនូវឯកសារ **E124/7.3** ឧបសម្ព័ន្ធ។ សូមអាន **E284** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, ទំព័រ៧០។

[7] **នួន ជា: E163/5/11** សេចក្ដីសន្និដ្ឋានបឋមពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ("សេចក្ដីសន្និដ្ឋានរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន")។ ***ខៀវ សំផន៖*** **E163/5/9** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ("សេចក្ដីសន្និដ្ឋានរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន")។

[8] **នួន ជា៖ E295/6/3** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល របស់ នួន ជា ក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ("សេចក្ដីសន្និដ្ឋានសវនាការរបស់ នួន ជា")។ **ខៀវ សំផន៖ E295/6/4** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ("សេចក្ដីសន្និដ្ឋានសវនាការរបស់ ខៀវ សំផន។

5. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១[9]។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន មានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃអំពើសម្លាប់រង្គាល (ដែលក្នុងនោះមាន ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១, អំពើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២, ការបាត់ខ្លួនដោយបង្ខំ) ទាក់ទងនឹងការជម្លៀសប្រជាជនទាំងពីរដំណាក់កាល និងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើសម្លាប់រង្គាល (ដោយរួមមានអំពើមនុស្សឃាត) និងការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ផ្អែកតាមទម្រង់នៃការទទួលខុសត្រូវនៃការរៀបចំផែនការ, ការបញ្ជា(ចំពោះតែ នួន ជា), ការញុះញង់ និងការជួយ និងការទំនុកបម្រុង, ក៏ដូចជាការទទួលខុសត្រូវរបស់ថ្នាក់លើ (ចំពោះតែ នួន ជា)[10]។

6. អង្គជំនុំជម្រះសាលាដំបូងបានដាក់ការផ្ដន្ទាទោសផ្អែកលើសហឧក្រិដ្ឋកម្មរួម (JCE) តែក្នុងផ្នែកដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ ការធ្វើមនុស្សឃាត (ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) តែប៉ុណ្ណោះ), ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដោយរួមមាន ការជម្លៀសដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងអំពើសម្លាប់រង្គាល (ដោយរួមមាន អំពើមនុស្សឃាត) ទាក់ទងនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ (“ការផ្ដន្ទាទោសតាម JCE”)។ អង្គជំនុំជម្រះសាលាដំបូងមិនបានដាក់ការផ្ដន្ទាទោស ចំពោះឧក្រិដ្ឋកម្មទាំងនោះផ្អែកលើការទទួលខុសត្រូវចំពោះការរៀបចំផែនការ, ការបញ្ជា, ការញុះញង់ ឬការជួយនិងការទំនុកបម្រុង[11] ឬចំពោះបទឧក្រិដ្ឋណាមួយពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះ នួន ជា ឡើយ[12], បើទោះបីជាបានរកឃើញថា ជនជាប់ចោទទទួលខុសត្រូវ ព្រហ្មទណ្ឌក្រោមទម្រង់នៃការទទួលខុសត្រូវទាំងនោះក៏ដោយ។

---

9 **E313** សំណុំរឿង០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (“សាលក្រម”)។

10 **E313** សាលក្រម, កថាខណ្ឌ៩៤០-៩៤២ (នួន ជា) និង ១០៥៣-១០៥៤ (ខៀវ សំផន)។

11 **E313** សាលក្រម, កថាខណ្ឌ ៩៤០ (នួន ជា) និង ១០៥៣ (ខៀវ សំផន)។

12 **E313** សាលក្រម, កថាខណ្ឌ៩៤១។

7. សម្រាប់ឧក្រិដ្ឋកម្មដែលនៅសេសសល់ (មានន័យថា (i) ការសម្លាប់រង្គាលទាក់ទងនឹងការជម្លៀសប្រជាជន (ដំណាក់កាលទី I); (ii) ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមានទាំងការបាត់ខ្លួនដោយបង្ខំទាក់ទងនឹងការជម្លៀសប្រជាជន (ដំណាក់កាលទី II) និង (iii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទាក់ទងនឹងទួលពោធិ៍ជ្រៃ ("ឧក្រិដ្ឋកម្មបន្ថែម") អង្គជំនុំជម្រះសាលាដំបូង បានធ្វើការកាត់ទោសដោយផ្អែកលើការធ្វើផែនការ, ការបញ្ជា (ចំពោះតែ នួន ជា), ការញុះញង់ និងការជួយ និងការទំនុកបម្រុង[13]។

8. នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤[14] ហើយបានដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគាត់តាមក្រោយដោយ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤[15]។

9. នៅនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ អជតក បានជូនដំណឹងដល់ភាគីថា ប្រសិនបើការសម្រេចដាក់ពិរុទ្ធភាព ត្រូវបានធ្វើឡើងនោះ អង្គជំនុំជម្រះអាច "ពិចារណា [...] កែប្រែបទចោទប្រកាន់ពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ទៅជាទម្រង់នៃការទទួលខុសត្រូវ ដែលអង្គជំនុំជម្រះយល់ថាសមស្រប អាចរួមទាំង ការទទួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម លើបទចោទទាំងអស់ដែលជនជាប់ចោទអាចនឹងត្រូវបានសម្រេចដាក់ពិរុទ្ធភាពនោះ។[16] អជតក បានស្នើឲ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សរប្រសិនបើមាន ទាក់ទងនឹងការកែប្រែ "បទចោទប្រកាន់" ដែលជាសក្តានុពល[17]។

---

[13] **E313** សាលក្រម, កថាខណ្ឌ៩៤២ (នួន ជា) និង ១០៥៤ (ខៀវ សំផន)។

[14] **នួន ជា: E313/1/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ២៩ កញ្ញា ២០១៤។ **ខៀវ សំផន: E313/2/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១, ២៩ កញ្ញា ២០១៤។

[15] **នួន ជា: F16** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ២៩ ធ្នូ ២០១៤ ("សារណាបណ្តឹងសាទុក្ខរបស់ នួន ជា")។ **ខៀវ សំផន: F17** សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ២៩ ធ្នូ ២០១៤ ("សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន")។

[16] **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការ, ទំព័រ៥(ភាសាអង់គ្លេស)។

[17] **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការ, ទំព័រ៥(ភាសាអង់គ្លេស)។

## III. ច្បាប់ជាធរមាន

10. វិធាន១១០(២)[18] ចែងថា "គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបន្ថែមធាតុផ្សំថ្មី នៃបទល្មើសណាមួយដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ"។

## I. សេចក្ដីសន្និដ្ឋាន

### *i. ច្បាប់ស្ដីពីការកំណត់បទចោទឡើងវិញ*

### ក. អជតក មានអំណាចប្ដូរការកំណត់បទចោទប្រកាន់

11. វិធាន១១០(២) ស្ថិតនៅក្នុងវិធាន១១០ នៃវិធានផ្ទៃក្នុង ដែលត្រូវបាននាំមុខដោយ៖ "អានុភាពនៃបណ្ដឹងសារទុក្ខ"។ តាមស្មារតីនៃ វិធាន១១០(២) នៃវិធានផ្ទៃក្នុង បានផ្ដល់អំណាចយ៉ាងច្បាស់លាស់ឲ្យ អជតក ដើម្បីកំណត់បទចោទប្រកាន់ឡើងវិញនៅដំណាក់កាលបណ្ដឹងសាទុក្ខ។ វាឆ្លុះបញ្ចាំងមាត្រា ៤០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងមានលក្ខណៈស្រដៀងគ្នាថា៖ "សាលាឧទ្ធរណ៍អាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុដែលសាលាដំបូងបានកំណត់ តែមិនត្រូវបន្ថែមធាតុថ្មីណាមួយ ដែលមិនបានដាក់ជូនតុលាការជាន់ដំបូងសម្រេចនោះទេ"។ វាក៏ឆ្លុះបញ្ចាំងពីច្បាប់របស់បារាំងផងដែរ[19]។

### ខ. គោលការណ៍ស្ដីពីការកំណត់បទចោទប្រកាន់ឡើងវិញ

---

18 វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៩, ១៦ មករា ២០១៥ ("វិធានផ្ទៃក្នុង")។

19 នៅក្នុងប្រទេសបារាំង យោងតាមគោលការណ៍ដែលថៅក្រមព្រហ្មទណ្ឌអាចកំណត់បទចោទប្រកាន់អង្គហេតុឡើងវិញ ដែលពួកគេត្រូវបានដាក់ជូននោះ អនុវត្តដូចគ្នាទៅនឹងតុលាការឧទ្ធរណ៍ ក្នុងលក្ខខណ្ឌដែលថាជនជាប់ចោទអាចការពារខ្លួនឯងដោយផ្ទាល់ ចំពោះការកំណត់បទចោទប្រកាន់ឡើងវិញដែលបានប្រមើលដឹងបាន។ សូមមើល *Code de Procédure Pénale*, បោះពុម្ពលើកទី៥៤, ២០១៣, ទំព័រ ៨៦៥, សេចក្ដីអត្ថាធិប្បាយលើមាត្រា ៥១២ នៃក្រម ដោយយោងសំអាង Crim. 3 មីនា ២០០៤: Bull. Crim. លេខ. 56។ D. 2004. IR 1213។ JCP ២០០៤. IV. 1967។ Dr Pénal ២០០៤. Comm. 138, obs. Maron។

12. ក្នុងការអនុវត្តអំណាចតាមវិធាន១១០(២) នៃវិធានផ្ទៃក្នុងរបស់ខ្លួន អជតក អាចទាញយកសេចក្តីណែនាំចេញពីគោលការណ៍នានា ទាក់ទងនឹងការកំណត់បទចោទឡើងវិញនៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលកើតចេញពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")។ ដូចបានពិភាក្សាបន្តទៀតខាងក្រោម តុលាការ ECtHR បានរកឃើញការកំណត់បទចោទឡើងវិញនៃបទល្មើស ឬទម្រង់មួយនៃការទទួលខុសត្រូវ នៅដំណាក់កាលចុងក្រោយនៃបណ្តឹងសាទុក្ខ ស្របគ្នាទៅនឹងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ("អនុសញ្ញាអឺរ៉ុប") បានផ្តល់ឲ្យជនជាប់ចោទមានឱកាសសមស្របដើម្បីបង្ហាញពីការការពារខ្លួនចំពោះបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានកំណត់បទចោទឡើងវិញនោះ។

13. គោលការណ៍ស្តីពីការកំណត់បទចោទប្រកាន់ឡើងវិញទាំងអស់នេះរួមមាន៖

ក. ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ត្រូវតែវាយតម្លៃស្របទៅនឹងកិច្ចដំណើរការនីតិវិធីទាំងមូល ដោយរួមទាំងនីតិវិធីបណ្តឹងសាទុក្ខផងដែរ[20]។

ខ. ចុងចោទមានសិទ្ធិទទួលបានការជូនដំណឹងលម្អិត មិនត្រឹមតែអំពីអំពើដែលគាត់ត្រូវបានចោទថាបានប្រព្រឹត្ត និងអំពីមូលដ្ឋាននៃការចោទប្រកាន់ប៉ុណ្ណោះទេ តែថែមទាំងអំពីការកំណត់បទចោទ

---

[20] រឿងក្តី *Dallos តទល់នឹង ហុងគ្រី* លេខ. 29082/95, សាលក្រម ថ្ងៃទី១ ខែមីនា ឆ្នាំ២០០១ ("Dallos"), កថាខណ្ឌ៤៧, ដោយយោងសំអាង *រឿងក្តី Miailh តទល់នឹង បារាំង* (លេខ ២), សាលក្រម ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៩៦ របាយការណ៍ 1996-IV, ទំព័រ. 1338, § 43, *និង រឿងក្តី Imbrioscia តទល់នឹង ស្វីស*, សាលក្រម ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣, សេរី A លេខ. 275, ទំព័រ 13-14, § 38។ *រឿងក្តី Sipavičius តទល់នឹង Lithuania*, លេខ. 49093/99, សាលក្រម, ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០២ ("*Sipavičius*"), កថាខណ្ឌ៣០។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានកត់សម្គាល់ថាយុត្តិសាស្ត្រ ECtHR បង្ហាញថា "ការប្តូរការកំណត់បទចោទប្រកាន់ឡើងវិញនៃអង្គហេតុ អាចត្រូវបានដោះស្រាយនៅដំណាក់កាលក្រោយនៃកិច្ចដំណើរការនីតិវិធី ដោយរួមបញ្ចូលទាំងដំណាក់កាលបណ្តឹងសាទុក្ខ ឬក្នុងការពិនិត្យឡើងវិញនូវកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការខ្ពស់បំផុតក្នុងស្រុក ដោយមិននាំឲ្យមានភាពអយុត្តិធម៌មិនចាំបាច់"។ សូមមើល ICC *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germain Katanga*, សាលក្រមលើបណ្តឹងសាទុក្ខ របស់លោក Germain Katanga ប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះ II ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ មានចំណងជើងថា "សេចក្តីសម្រេចលើការអនុវត្តបទប្បញ្ញត្តិលេខ ៥៥ នៃបទប្បញ្ញត្តិរបស់តុលាការ និងការបំបែកបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ", ICC-01/04-01/07 OA 13, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ("សាលដីកាបណ្តឹងសាទុក្ខ *Katanga*") កថាខណ្ឌ៩៣។

ប្រកាន់ដែលត្រូវបានផ្តល់ជូនចំពោះអំពើទាំងអស់នោះផងដែរ[21]។ បទប្បញ្ញត្តិនៃព័ត៌មានលម្អិតពេញលេញ ទាក់ទងនឹងបទចោទប្រកាន់ និងការកំណត់បទចោទប្រកាន់ដែលតុលាការអាចអនុម័តយកក្នុងបញ្ហានេះ គឺជាបុរេលក្ខខណ្ឌជាសារវន្តសម្រាប់ការធានាថាកិច្ចដំណើរការនីតិវិធីមានយុត្តិធម៌[22]។

គ. សិទ្ធិទទួលបានការជូនដំណឹងនៃលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់ត្រូវតែពិចារណាពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនជាប់ចោទដើម្បីត្រៀមការការពារខ្លួនរបស់គាត់[23]។

ឃ. អង្គជំនុំជម្រះគួរពិចារណាថាតើ ការការពារខ្លួនចំពោះបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានកំណត់បទចោទឡើងវិញ អាចខុសប្លែកពីការការពារក្តីចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ ឬទេ[24]។

ង. អង្គជំនុំជម្រះគួរពិចារណា ថាតើបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានកំណត់បទចោទប្រកាន់ឡើងវិញ មានធាតុផ្សំថ្មីភ្ជាប់ទៅនឹងការចោទប្រកាន់បឋមដែលអ្នកដាក់ពាក្យប្តឹងបានដឹង ឬទេ[25]។

ច. ដោយហេតុថាបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានកំណត់បទចោទប្រកាន់ឡើងវិញ រួមបញ្ចូលនូវធាតុផ្សំថ្មីនោះ អង្គជំនុំជម្រះគួរពិចារណាថាតើជនជាប់ចោទត្រូវបានផ្តល់ជូននូវឱកាសដើម្បីបង្ហាញការការពារក្តីចំពោះធាតុផ្សំថ្មីនោះ ក្នុងលក្ខណៈពិតប្រាកដ និងមានប្រសិទ្ធិភាព ហើយនៅក្នុងពេលវេលាដ៏ល្អ ឬទេ[26]។

---

[21] *រឿងក្តី* Pélissier និង Sassi *តទល់នឹង បារាំង*, លេខ 25444/94, សាលក្រម ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ (“*Pélissier*”), កថាខណ្ឌ៥១។ *Dallos*, កថាខណ្ឌ៤៧។ *Sipavičius*, កថាខណ្ឌ២៧។

[22] *Dallos*, កថាខណ្ឌ៤៧។ *Sipavičius*, កថាខណ្ឌ២៨។

[23] *Pélissier*, កថាខណ្ឌ៥១។ *Sipavičius*, កថាខណ្ឌ២៨។

[24] *Pélissier*, កថាខណ្ឌ៦០។

[25] *Pélissier* កថាខណ្ឌ៦១៖ “តាមអ្វីដែលបានលើកឡើង តុលាការក៏រកឃើញថា ការជួយនិងការទំនុកបម្រុង មិនបានបង្កើតឱ្យមានធាតុផ្សំភ្ជាប់ទៅនឹងការចោទប្រកាន់បឋម ដែលអ្នកដាក់ពាក្យប្តឹងបានដឹងពីដើមដំបូងនៃកិច្ចដំណើរការនីតិវិធីនោះទេ”។

[26] *រឿងក្តី* Block *តទល់នឹង ហុងគ្រី*, លេខ. 56282/09, សាលក្រម ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ២៤។ *Pélissier*, កថាខណ្ឌ៦២។ *រឿងក្តី* Drassich *តទល់នឹង អ៊ីតាលី*, លេខ 25575/04, សាលក្រម ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ៣៤, ៤០។ ការណ៍នេះក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ នៅក្នុងបទប្បញ្ញត្តិ ៥៥(២) នៃបទប្បញ្ញត្តិ ICC៖ “អង្គជំនុំ

ឆ. សេចក្តីជូនដំណឹងអំពីការកំណត់បទចោទឡើងវិញ នៅដំណាក់កាលចុងក្រោយនៃដំណើរការនីតិវិធី ខ្លួនវាផ្ទាល់មិនរំលោភសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌ទេ[27]។

ជ. ប្រសិនបើជនជាប់ចោទត្រូវបានកាត់ឲ្យជាប់ទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មណាមួយដែលខុសគ្នាពីធាតុផ្សំជាក់ស្តែងចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ នោះជនជាប់ចោទត្រូវតែបានទទួលបាននូវឱកាសដោយយុត្តិធម៌ ដើម្បីបង្ហាញនូវការការពារខ្លួនទាក់ទងនឹងធាតុផ្សំបន្ថែមទាំងនោះ។ ក្នុងរឿងក្តី *Dallos,* តុលាការ ECtHR បានតម្កល់ទោសដែលបានកាត់ចំពោះបទល្មើសមួយដែលត្រូវបានកំណត់ឡើងវិញ នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខដោយសារតែជនជាប់ចោទរូបនោះ "មានឱកាសដើម្បីពន្លើននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល [របស់ប្រទេសហុងហ្គារី] នូវការការពារខ្លួនគាត់ទាក់ទងនឹងបទចោទប្រកាន់ដែលបានប្តូរទម្រង់"[28]។ តុលាការនេះបានសម្រេចថា ដោយមានការវាយតម្លៃលើភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងមូល វិការៈណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការជាន់ទាប ត្រូវបានដោះស្រាយនៅចំពោះមុខតុលាការកំពូលរបស់ប្រទេសហុងហ្គារី។ ក្នុងរឿងក្តី *Sipavičius*, តុលាការបានសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខមានឱកាសដើម្បីពន្លើននៅចំពោះមុខតុលាការឧទ្ធរណ៍ និងតុលាការកំពូលរបស់ប្រទេស Lithuania នូវការការពារខ្លួនរបស់គាត់ទាក់ទងនឹងបទចោទប្រកាន់ដែលបានប្តូរទម្រង់។ ទាំងក្នុងរឿងក្តី *Dallos* និងរឿងក្តី *Sipavičius* តុលាការសុទ្ធតែបានសម្រេចថា គ្មានការរំលោភសិទ្ធិសញ្ញាអឺរ៉ុបឡើយ។

---

ជម្រះអាចពន្យារពេលសវនាការដើម្បីធានាឲ្យបានថា អ្នកចូលរួមមានពេលវេលា និងធនធានគ្រប់គ្រាន់សម្រាប់ការរៀបចំដ៏មានប្រសិទ្ធភាព ឬ ប្រសិនបើចាំបាច់ អង្គជំនុំជម្រះអាចបង្គាប់ឲ្យមានសវនាការមួយដើម្បីពិចារណាវាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការប្តូរដែលត្រូវបានស្នើឡើងនោះ"។ បទប្បញ្ញត្តិ ៥៥(៣) តម្រូវឲ្យអង្គជំនុំជម្រះធានាថា ជនជាប់ចោទមាន 'ពេលវេលា និងធនធានគ្រប់គ្រាន់សម្រាប់ការរៀបចំដ៏មានប្រសិទ្ធភាពនៃការការពារខ្លួនរបស់គាត់' ប្រសិនបើចាំបាច់ដោយរួមមានឱកាសហៅសាក្សីឡើងវិញ និងដើម្បីបង្ហាញភ័ស្តុតាងផ្សេងទៀត។ *សូមមើលផងដែរ* សាលដីកាបណ្តឹងសាទុក្ខ *Katanga* ស្តីពីការកំណត់បទចោទឡើងវិញ កថាខណ្ឌ៩៥៖ "ការពិចារណាបែបនោះ អាចរួមបញ្ចូលការវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង ថាតើ លោក *Katanga* តាមពិត ត្រូវបានរងនូវភាពអយុត្តិធម៌ដោយការកំណត់បទចោទប្រកាន់ឡើងវិញមួយ ដែលត្រូវបានធ្វើឡើងនៅដំណាក់កាលនេះឬទេ ជាពិសេស រួមទាំងថាតើ គាត់ត្រូវបានដកហូតនូវរបាំងការពារក្តី ទាក់ទងនឹងមាត្រា ២៥(៣)(ឃ) នៃលក្ខន្តិកៈ [ICC] ដែលរូបគាត់ពុំនោះសោតទេ បានមានបំណងចង់បង្ហាញ ឬយ៉ាងណា"។

27 *Katanga* សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការកំណត់បទចោទឡើងវិញ, កថាខណ្ឌ៩៤។

28 *Dallos*, កថាខណ្ឌ៥២។

## គ. ការកំណត់បទចោទឡើងវិញអំពីការកាត់ឲ្យជាប់ទោសតាម JCE

14. ដីកាកំណត់កាលបរិច្ឆេទសវនាការ យោងដល់ការទទួលខុសត្រូវរបស់ អជតក ក្នុងការការកំណត់បទចោទជាថ្មីឡើងវិញ "ជាទម្រង់នៃការទទួលខុសត្រូវ ដែលអង្គជំនុំជម្រះ យល់ឃើញថាសមស្រប"[29]។ អជតក មានឆន្ទានុសិទ្ធ ទៅតាមវិធាន១១០ នៃវិធានផ្ទៃក្នុង ក្នុងការកំណត់បទចោទជាថ្មីលើការ កាត់ឲ្យជាប់ទោសតាម JCE ដែលបានកត់ចូលដោយអង្គជំនុំជម្រះសាលាដំបូង និងក្នុងការដាក់ចូលនូវការកាត់ឲ្យជាប់ទោសចំពោះឧក្រិដ្ឋកម្មទាំងនោះ នៅក្រោមទម្រង់ណាមួយផ្សេងទៀតនៃការទទួលខុស។

15. នៅក្នុងបណ្តឹងសាទុក្ខលើករណីរបស់ *ឌុច* អជតក បានយោងដល់អំណាចរបស់ខ្លួន តាមវិធាន ១១០(២)។ ការណ៍នេះបានលេចឡើងនៅក្នុងបរិបទនៃការកំណត់ "ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការសន្និដ្ឋានថា ពិរុទ្ធភាពពីបទល្មើសត្រួតគ្នាចំពោះការធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មនានាដែលប្រឆាំងមនុស្សជាតិ មិនត្រូវបានអនុញ្ញាតដែរឬយ៉ាងណា"[30]។ អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានរកឃើញភាពចាំបាច់ក្នុងការកាត់ឲ្យ ជាប់ទោសចំពោះឧក្រិដ្ឋកម្មនានាដែលប្រឆាំងមនុស្សជាតិ គឺមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និង អំពើអមនុស្សធម៌ផ្សេងៗទៀត ក៏ប៉ុន្តែបានកត់ចូលតែការកាត់ ឲ្យជាប់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ។ អជតក បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីស្រូបបញ្ចូលគ្នានូវឧក្រិដ្ឋកម្មនីមួយៗឲ្យស្ថិតនៅក្រោមការធ្វើទុក្ខបុកម្នេញ[31]។ ជាការបន្ថែមទៅនឹងការកាត់ឲ្យជនជាប់ចោទជាប់ទោសពីបទការធ្វើទុក្ខបុកម្នេញ អជតក បានកត់ចូលនូវការកាត់ឲ្យជាប់ទោសដោយឡែកៗ ចំពោះឧក្រិដ្ឋកម្មនីមួយៗដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹង

---

[29] **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការ, ទំព័រ៥។

[30] សំណុំរឿង០០១-**F28** សាលដីកា, ០៣ កុម្ភៈ ២០១២ ("សាលដីកាលើករណីរបស់ ឌុច"), កថាខណ្ឌ៨៨។

[31] អជតក បានសរសេរថា "ការស្រូបបញ្ចូលបទល្មើសមូលដ្ឋានទាំងអស់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានរក ឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវ ទៅក្នុងការសម្រេចដាក់ពិរុទ្ធភាពតែពីបទធ្វើទុក្ខបុកម្នេញ ដោយពុំបានសម្រេចដាក់ ពិរុទ្ធភាពត្រួតគ្នានោះ គឺជាការសម្រេច ពុំបានដោះស្រាយឲ្យបានគ្រប់គ្រាន់ពីព្យសនកម្មចំពោះផលប្រយោជន៍នីមួយៗនៅក្នុង សង្គម ដែលមានបញ្ញត្តិការពារដែលបទប្បញ្ញត្តិទាំងនេះបានចែងពីបទឧក្រិដ្ឋខុសៗគ្នានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។ សំណុំរឿង០០១-**F28** សាលដីកាលើករណីរបស់ ឌុច, កថាខណ្ឌ៣៣១។

មនុស្សជាតិ[32]។ នៅក្នុងកំណត់សម្គាល់ជើងទំព័រមួយ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា "ការបញ្ចូលការសម្រេចដាក់ពិរុទ្ធភាពជាផ្លូវការនៅទីនេះ គឺអនុលោមតាមវិធាន១១០(២) នៃវិធានផ្ទៃក្នុង និងមាត្រា៤០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលតុលាការឧទ្ធរណ៍ អាចកែប្រែបទចោទ ដោយមិនត្រូវបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយ ដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ"[33]។

16. ក្នុងករណីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញនៅក្នុងសាលក្រមថា ការចូលរួមរបស់ជនជាប់ចោទក្នុង JCE មានរួមបញ្ចូលទាំងទង្វើប្រព្រឹត្តទាំងអស់ដែលបង្កើតបានជាមូលដ្ឋាននៃរបបគំហើញនានារបស់អង្គជំនុំជម្រះ ចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត និងថាដូច្នេះ អង្គជំនុំជម្រះបានសម្រេចកាត់ទោសចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះតាមរយៈតែ JCE មួយប៉ុណ្ណោះ[34]។ អជតក មានឆន្ទានុសិទ្ធិដើម្បីកំណត់បទចោទឡើងវិញស្របតាមវិធាន១១០ នៃវិធានផ្ទៃក្នុង ចំពោះការកាត់ទោស JCE និងដើម្បីសម្រេចលើការកាត់ទោសតាមទម្រង់នៃការទទួលខុសត្រូវ។

### *ii.* ការអនុវត្តគោលការណ៍ស្តីពីការកំណត់បទចោទឡើងវិញចំពោះឧក្រិដ្ឋកម្មបន្ថែម

17. ដោយអនុវត្តតាមគោលការណ៍ខាងលើចំពោះករណីបច្ចុប្បន្ន (និងដូចដែលបានដាក់យ៉ាងលម្អិតខាងក្រោម) វាមានការពាក់ព័ន្ធសម្រាប់អង្គជំនុំជម្រះពិចារណាថា ជនជាប់ចោទទាំងពីរ៖

ក. ត្រូវបានផ្តល់ជូននូវព័ត៌មានយ៉ាងលម្អិត និងពេញលេញថា ពួកគាត់អាចនឹងត្រូវបានកាត់ទោសនៅក្រោមទម្រង់នៃការទទួលខុសត្រូវ JCE ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ តាំងពីដំណាក់កាលដើមដំបូងនៃកិច្ចដំណើរការនីតិវិធី។

ខ. បានធ្វើសេចក្តីសន្និដ្ឋានយ៉ាងទូលំទូលាយនៅក្នុងអំឡុងពេលសវនាការ និងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ចំពោះទម្រង់នៃការទទួលខុសត្រូវ JCE និងធាតុផ្សំអង្គហេតុ និងអង្គច្បាប់នៃឧក្រិដ្ឋកម្ម។

---

32 សំណុំរឿង០០១-**F28** សាលដីកាលើករណីរបស់ ឌុច, កថាខណ្ឌ៣៣៦។

33 សំណុំរឿង០០១-**F28** សាលដីកាលើករណីរបស់ ឌុច, កំណត់សម្គាល់ជើងទំព័រលេខ៧៣៥។

34 **នួន ជា៖ E313** សាលក្រម កថាខណ្ឌ៩៤០។ **ខៀវ សំផន៖ E313** សាលក្រម កថាខណ្ឌ១០៥៣។

គ. បានទទួលឱកាសសមស្របក្នុងអំឡុងសវនាការដើម្បីធ្វើឲ្យជឿនលឿនការការពារក្តីចំពោះការទទួលខុសត្រូវ JCE ទាក់ទងនឹងរាល់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៅតាមរបៀបមួយដែលអនុវត្តបាន និងមានប្រសិទ្ធភាព និងក្នុងពេលវេលាល្អ។

ឃ. បានដឹកនាំអនុវត្តការការពារខ្លួនពិតប្រាកដមែនក្នុងអំឡុងសវនាការ ដោយឈរលើមូលដ្ឋានថាពួកគាត់ត្រូវបានចោទប្រកាន់អំពីការប្រព្រឹត្តិទម្រង់នៃការទទួលខុសត្រូវ JCE ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងអស់ រួមទាំងឧក្រិដ្ឋកម្មបន្ថែម ឬបានការពារខ្លួនឯងតាមរបៀបមួយដែលអាចអនុវត្តបានជាទូទៅចំពោះបទល្មើសជាមូលដ្ឋានទាំងអស់។

ង. ត្រូវបានជូនដំណឹង (តាមរយៈដីកាកំណត់កាលបរិច្ឆេទសវនាការ) ថា អង្គជំនុំជម្រះអាចពិចារណាផ្លាស់ប្តូរការកំណត់បទចោទ ទៅជាទម្រង់នៃការទទួលខុសត្រូវណាមួយដែលខ្លួនយល់ថាសមស្រប រួមបញ្ចូលជាសំខាន់ទាំងការទទួលខុសត្រូវ JCE ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលការកាត់ទោសចំពោះឧក្រិដ្ឋកម្មទាំងនោះ អាចនឹងត្រូវតម្កល់ ហើយត្រូវបានផ្តល់ឱកាសធ្វើសារណាជាច្រើននៅលើការកំណត់បទចោទឡើងវិញសក្តានុពលនេះ[35]។

## ក. អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលការរកឃើញពិស្តារអំពីអត្ថិភាពនៃ JCE និងការចូលរួមរបស់ជនជាប់ចោទនៅក្នុង JCE

18. កង្វល់ផ្សេងៗដែលគូសបញ្ជាក់នៅក្រោមយុត្តិសាស្ត្ររបស់ ECtHR ទាក់ទិននឹងការនាំទៅដល់ការកាត់ឲ្យជាប់ទោស លើបណ្តឹងសាទុក្ខចំពោះទម្រង់នៃការទទួលខុសត្រូវមួយ ដែលមានលក្ខណៈខុសគ្នាយ៉ាងជាក់ស្តែងពីទម្រង់នៃការទទួលខុសត្រូវ ដែលជនជាប់ចោទបានដឹកនាំការការពារខ្លួននោះ[36] មិនអាចអនុវត្តបានទេនៅទីនេះ។

19. ដើម្បីកាត់ទោសជនជាប់ចោទចំពោះឧក្រដ្ឋិកម្មបន្ថែម ដោយផ្អែកលើការចូលរួមប្រព្រឹត្តរបស់ពួកគេនៅក្នុង JCE ណាមួយ (ទម្រង់ជាមូលដ្ឋាន ឬ JCE I) អជតក ត្រូវតែរកឲ្យឃើញថា ពិតជា

[35] **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការ, ទំព័រ៥។

[36] ជាឧទាហរណ៍ តុលាការ ECtHR បានរកឃើញការរំលោភមាត្រា៦ ដែលជនជាប់ចោទត្រូវបានកាត់ឲ្យជាប់ទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ ចំពោះអំពើប៉ុនប៉ងបោកបន្លំ ប៉ុន្តែត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងទទួលសំណូកវិញ: ដែលនេះជាឧក្រិដ្ឋកម្មដែលតុលាការ ECtHR បាននិយាយថាមាន *"ភាពខុសគ្នាដ៏សំខាន់នៅក្នុងធាតុផ្សំអត្តនោម័ត និងសត្យានុម័ត"*៖ *Seliverstov ទល់នឹងប្រទេសរុស្ស៊ី,* លេខ 19692/02, សាលក្រម, ២៥ ធ្នូ ២០០៨ ("*Seliverstov*"), កថាខណ្ឌ១៩។

មានពហុភាពនៃបុគ្គល[37] ដែលនេះជាគោលបំណងរួមមានតម្លៃស្មើនឹង ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មបន្ថែម[38] និងថា ជនជាប់ចោទបានចូលរួមប្រព្រឹត្តនៅក្នុងគោលបំណងរួម ហើយបានចូលរួមបរិច្ឆាកសំខាន់[39]។ ការរួមចំណែករបស់ជនជាប់ចោទ មិនចាំបាច់ជារឿងព្រហ្មទណ្ឌទេ ប៉ុន្តែត្រូវតែបានជួយពន្លឿនដល់គោលបំណងរួម (មិនចាំបាច់ចំពោះតែឧក្រិដ្ឋកម្មជាក់លាក់កំពុងនិយាយនេះទេ)[40]។ ការចូលរួមនៅក្នុង JCE អាចនាំមកនូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិក JCE ប្រសិនបើគេអាចបង្ហាញថាឧក្រិដ្ឋកម្មទាំងនោះអាចទំលាក់ការទទួលខុសត្រូវលើយ៉ាងហោចណាស់សមាជិកម្នាក់នៃ JCE[41]។ ចំពោះ *បំណងទុច្ចរិត* វិញ ជនជាប់ចោទត្រូវតែមានចេតនាចូលរួមប្រព្រឹត្តនៅក្នុងបំណងរួម ហើយចេតនានេះទៀតសោត ត្រូវតែបានចែករំលែកជាមួយអ្នកចូលរួមប្រព្រឹត្ត JCE ដទៃទៀត[42]។

20. អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលការរកឃើញលម្អិតស្តីពីធាតុផ្សំ JCE ។ អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលការរកឃើញតាមរយៈពេលមួយ ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១នេះមានពហុភាពនៃបុគ្គលនានាដែលបានរួមចំណែកនូវគោលបំណងរួម ក្នុងការអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័សតាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ" និងក្នុងការការពារបក្សប្រឆាំងនឹងពួកខ្មាំងខាងក្នុង និងខាងក្រៅ ដោយមធ្យោបាយចាំបាច់ណាក៏ដោយ និងអ្នកចូលរួមទាំងឡាយ រួម

[37] **E313** សាលក្រម, កថាខណ្ឌ៦៩២ *យោង*សំណុំរឿង០០១-**E188** សាលក្រម, ២៦ កក្កដា ២០១០ ("សាលក្រម ឌុច"), កថាខណ្ឌ ៥០៨។ *រដ្ឋអាជ្ញា ទល់នឹង Krajišnik,* IT-00-39-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា, ១៧ មីនា ២០០៩ (សាលដីកា *Krajišnik*"), កថាខណ្ឌ ១៥៦។ *រដ្ឋអាជ្ញា ទល់នឹង Tadić,* IT-94-1-A, សាលាឧទ្ធរណ៍, សាលដីកា, ១៥ កក្កដា ១៩៩៩ ("សាលដីកា *Tadić*"), កថាខណ្ឌ២២៧។

[38] **E313** សាលក្រម, កថាខណ្ឌ៦៩២ *យោង*សំណុំរឿង០០១-**E188** សាលក្រមឌុច, កថាខណ្ឌ ៥០៨។ សាលដីកា *Tadić* កថាខណ្ឌ ២២៧។

[39] **E313** សាលក្រម, កថាខណ្ឌ៦៩២។ *យោង*សំណុំរឿង០០១-**E188** សាលក្រមឌុច, កថាខណ្ឌ ៥០៨។ រដ្ឋអាជ្ញា ទល់នឹង *Brđanin,* IT-99-36-A, សាលាឧទ្ធរណ៍, សាលដីកា, ២ មេសា ២០០៧, កថាខណ្ឌ៤៣០។ សូមអានផងដែរ សាលដីកា *Tadić* កថាខណ្ឌ២២៧។

[40] **E313** សាលក្រម, កថាខណ្ឌ ៦៩៣ *យោង រដ្ឋអាជ្ញា ទល់នឹង Vasiljević,* IT-98-32-A, សាលាឧទ្ធរណ៍, សាលដីកា, ២៥ កុម្ភៈ ២០០៤, កថាខណ្ឌ ១០០។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Tadić,* IT-94-1-A, សាលាឧទ្ធរណ៍, សាលដីកា, ១៥ កក្កដា ១៩៩៩, កថាខណ្ឌ២២៩។

[41] **E313** សាលក្រម, កថាខណ្ឌ៦៩៣ *យោង* សាលដីកា *Krajišnik* កថាខណ្ឌ២២៥។

[42] **E313** សាលក្រម, កថាខណ្ឌ៦៩៤ *យោង*សំណុំរឿង០០១-**E188** សាលក្រមឌុច, កថាខណ្ឌ ៥០៩។ រដ្ឋអាជ្ញា ទល់នឹង *Kvočka និងគូកន,* IT-98-30/1-A, សាលាឧទ្ធរណ៍, សាលដីកា, ២៨ កុម្ភៈ ២០០៥, កថាខណ្ឌ៨២, ១១៨។

មាន នួន ជា និង ខៀវ សំផន[43]។ អង្គជំនុំជម្រះនេះក៏បានរកឃើញ ផងដែរថា មាន JCE មួយ ដើម្បីឲ្យបានសម្រេចនូវគោលបំណងរួម ក្នុងចំណោមមធ្យោបាយផ្សេងៗនោះ គឺគោលនយោបាយនានាក្នុងការផ្លាស់ប្តូរដោយបង្ខំនូវទីលំនៅរបស់ប្រជាជនពីទីក្រុង និងទីរួមខេត្តនានា និងរវាងទីកន្លែងនានានៅតាមជនបទ[44]។ គេបានរកឃើញថា ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តក្នុងរយៈកាលនៃដំណើរការផ្លាស់ប្តូរទីលំនៅប្រជាជន (ដំណាក់កាលទី I និងដំណាក់កាលទី II) ត្រូវបានអនុវត្តតាម ដោយការធ្វើឲ្យជឿនលឿនទៅមុខនូវផែនការ និងគោលនយោបាយរបស់បក្ស[45]។ អង្គជំនុំជម្រះនេះក៏បានរកឃើញផងដែរឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ក្នុងអំឡុងពេលនៃរយៈកាលនៃការជម្លៀសដោយបង្ខំ (ដំណាក់កាលទីI និងទីII) អាចពាក់ព័ន្ធនឹងអ្នកចូលរួមក្នុងទម្រង់នៃ JCE[46]។ អង្គជំនុំជម្រះបានរកឃើញផងដែរថា មាន JCE ក្នុងការសម្រេចបាននូវគោលបំណងរួមតាមរយៈមធ្យោបាយផ្សេងៗទៀត គឺគោលនយោបាយផ្តោតចំពោះអតីតមន្ត្រីសាធារណរដ្ឋខ្មែរ[47]។ អង្គជំនុំជម្រះបានរកឃើញថាការសម្លាប់ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃអនុវត្តបន្ថែមលើផែនការ និងគោលនយោបាយរបស់បក្ស ហើយថា ឧក្រិដ្ឋកម្មទាំងនេះអាចពាក់ព័ន្ធនឹងយ៉ាងហោចណាស់សមាជិកម្នាក់នៃ JCE[48]។ អង្គជំនុំជម្រះរកឃើញថា នួន ជា និង ខៀវ សំផន បានធ្វើវិភាគទានសំខាន់មួយចំពោះការសម្រេចបាននូវផែនការរួមនេះ ហើយថាពួកគាត់មានចេតនាធ្វើឲ្យជឿនលឿនទៅមុខទៀត នូវការអនុវត្តគោលបំណងរួម តាមរយៈសកម្មភាពនានារបស់ពួកគាត់[49]។

## ខ. ជនជាប់ចោទ ត្រូវបានជូនដំណឹងថា ខ្លួនត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មបន្ថែម អនុលោមតាម JCE

21. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត (“សចស”) បានចោទប្រកាន់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្ម*ទាំងអស់* ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដោយឈរលើមូលដ្ឋាននៃទម្រង់នៃ JCE។

[43] **E313** សាលក្រម, កថាខណ្ឌ៧៧៧។

[44] **E313** សាលក្រម, កថាខណ្ឌ៧៨៦, ៨០៤-៨០៥។

[45] **E313** សាលក្រម, កថាខណ្ឌ ៨០៤-៨០៥។

[46] **E313** សាលក្រម, កថាខណ្ឌ ៨០៦-៨១០។

[47] **E313** សាលក្រម, កថាខណ្ឌ៨៣៥។

[48] **E313** សាលក្រម, កថាខណ្ឌ៨៣៥-៨៣៦។

[49] **E313** សាលក្រម, កថាខណ្ឌ៨៦១-៨៧៧ និង ៩៦០-៩៩៦។

22. ទម្រង់ JCE មាននៅក្នុងដីកាដំណោះស្រាយ បានឆ្លុះបញ្ចាំងនៅក្នុងការរកឃើញនៅក្នុងសាលក្រម ដូចបានលើកឡើងខាងលើ។ យោងទៅតាមដីកាដំណោះស្រាយ "គោលបំណងរួមរបស់មេដឹកនាំ បកក គឺដើម្បីអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័សនៅកម្ពុជា តាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" និងដើម្បីការពារបក្សប្រឆាំងនឹងខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ តាមមធ្យោបាយចាំបាច់ណាក៏ដោយ"[50]។ ខណៈដែលសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា គោលបំណងនេះខ្លួនវាផ្ទាល់ "មានចរិកមិនព្រហ្មទណ្ឌទាំងស្រុងក៏ដោយ"[51] តែត្រូវបានពិចារណាថាដើម្បីសម្រេចបានគោលបំណងនេះ មេដឹកនាំ បកក បានផ្ដើបង្កើត និងអនុវត្តគោលនយោបាយចំនួនប្រាំ[52] ដែលការអនុវត្តគោលនយោបាយទាំងនេះ "បានបង្កឲ្យមាន និង/ឬ បានពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង អំពើប្រល័យពូជសាសន៍[53]។ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ អនុលោមតាមគោលនយោបាយទាំងប្រាំនេះជាសមូហភាព រួមមាន*ឧក្រិដ្ឋកម្ម* ទាំងអស់ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១[54]។ តាមពិត ដីកាដំណោះស្រាយចែងចំៗថា នួន ជា និង ខៀវ សំផន បានប្រព្រឹត្តអំពើឧក្រិដ្ឋទាំងអស់ដូចបានរាយឈ្មោះក្នុងដីកាដំណោះស្រាយ តាមរយៈសមាជិកភាពរបស់ពួកគេនៅក្នុង JCE និងការរួមចំណែករបស់ពួកគាត់ទៅក្នុងគោលបំណងរួម និងបានចែករំលែកជាមួយសមាជិក JCE ដទៃទៀត នូវចេតនាធ្វើឲ្យឧក្រិដ្ឋកម្ម

---

50 **D427** ដីកាដំណោះស្រាយ,កថាខណ្ឌ១៥៦ កថាខណ្ឌ១៥២៤។

51 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៦, ១៥២៤។

52 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៧, ១៥២៥។ គោលនយោបាយទាំងប្រាំ មាន: (i) ការផ្លាស់ទីលំនៅប្រជាជនម្ដងហើយម្ដងទៀតពីទីក្រុង និងទីប្រជុំជននានា ទៅកាន់តំបន់ជនបទ ព្រមទាំងពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ("គោលនយោបាយផ្លាស់ទីលំនៅប្រជាជន")។ (ii) ការបង្កើត និងប្រតិបត្តិការនៃសហករណ៍ និងទីតាំងការដ្ឋាន។ (iii) ការអប់រំកែប្រែ "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងក្នុងជួរបក្ស និងក្រៅជួរបក្ស ("គោលនយោបាយអប់រំកែប្រែ និងការសម្លាប់ខ្មាំង")។ (iv) ការកំណត់ក្រុមគោលដៅជាក់លាក់ ជាពិសេស ចាម វៀតណាម ពុទ្ធសាសនិកជន និងអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរដ្ឋការស៊ីវិល និងអតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ។ (v) ការបញ្ញត្តិនៃការរៀបការ ("គោលនយោបាយកំណត់ក្រុមគោលដៅ")។

53 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥២៥។

54 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥២៥។ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបញ្ជូនដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារប្រឆាំងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលឧក្រិដ្ឋកម្មទាំងអស់នេះសុទ្ធតែត្រូវបានចោទប្រកាន់ដោយផ្អែកលើ JCE។

ដូចបានចោទប្រកាន់ទាំងអស់ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃគោលបំណងរួមនោះ[55]។ ជាក់លាក់ជាងនេះ គេច្បាស់ណាស់ថាទាក់ទងការជម្លៀសប្រជាជន (ដំណាក់កាលទី I និង II) និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ *រួមទាំងឧក្រិដ្ឋកម្មបន្ថែម* ផងដោយផ្អែកលើ JCE[56]។

23. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបំបែកសំណុំរឿង០០២ ដោយនាំមកតែការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និង II) និងក្រោយមកទៀត ទួលពោធិ៍ជ្រៃស្ថិតក្នុងវិសាលភាពនៃ

---

55 **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៤០។

56 **ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និង II)**: អនុលោមតាមឯកសារ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥២៥, តាមរយៈការអនុវត្តគោលនយោបាយផ្លាស់ទៅលំនៅប្រជាជន ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទអំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារប្រឆាំងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបញ្ជូនដោយបង្ខំ។ ដីកាដំណោះស្រាយ, កថាខណ្ឌ២០៩ បានភ្ជាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះមួយចំនួនក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីមួយនិងទីពីរ ទៅនឹងការអនុវត្តគោលនយោបាយកំណត់ក្រុមគោលដៅ ដែលបើយោងតាមដីកាដំណោះស្រាយ "បានបង្កឱ្យមាន និង/ឬ បានពាក់ព័ន្ធ" នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ (i) *ការសម្លាប់រង្គាល* និង (ii) អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈ*ការបាត់ខ្លួនដោយបង្ខំ*។ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨១-១៣៨៣, ១៣៨៧-១៣៩០ បញ្ជាក់អះអាងថា ការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និង II) គឺជា "ផ្នែកដ៏សំខាន់មួយនៃធម្មោបាយដែលបានប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការកម្ទេចខ្មាំង។ [...] គោលនយោបាយទាំងនេះត្រូវបានសម្រេច និងសម្របសម្រួលដោយមេដឹកនាំ បកក នៅក្នុងក្របខណ្ឌនៃគោលបំណងរួម"។ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៤៧០-១៤៧៨ បញ្ជាក់អះអាងថា អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំដែលបានប្រព្រឹត្តក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី II) "បង្កើតបានជា "ផ្នែកដ៏សំខាន់មួយនៃធម្មោបាយដែលបានប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណងរួម ក្នុងបំណងដើម្បីកម្ទេចខ្មាំង។ គោលនយោបាយទាំងនេះត្រូវបានសម្រេច និងសម្របសម្រួលដោយមេដឹកនាំ បកក នៅក្នុងក្របខណ្ឌនៃគោលបំណងរួម"។ **ទួលពោធិ៍ជ្រៃ**: **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ១៧៨ ភ្ជាប់យ៉ាងច្បាស់ក្រឡៃតទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ទៅនឹងគោលនយោបាយអប់រំកែប្រែ និងការសម្លាប់ខ្មាំង ដែលការអនុវត្តនេះ បើតាមដីកាដំណោះស្រាយកថាខណ្ឌ១៥២៥ "បានបង្កឱ្យមាន និង/ឬ បានពាក់ព័ន្ធ" នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅទីតាំងសម្លាប់មនុស្ស ទួលពោធិ៍ជ្រៃ: ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត *និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*។ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤១៦-១៤១៧, ១៤២៤-១៤២៥ កំណត់ថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ គឺជា "ផ្នែកដ៏សំខាន់មួយនៃធម្មោបាយដែលបានប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការកម្ទេចខ្មាំង ដែលក្នុងនោះ វាគឺជាវិធានការមួយក្នុងចំណោមវិធានការនានាដែលប្រឆាំងដោយផ្ទាល់នឹងក្រុមជាក់លាក់ណាមួយ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានសម្រេច និងសម្របសម្រួលដោយមេដឹកនាំ បកក នៅក្នុងក្របខណ្ឌនៃគោលបំណងរួម"។

សំណុំរឿង០០២/០១ នោះ អង្គជំនុំជម្រះបានណែនាំភាគីថា គោលនយោបាយតែពីរប៉ុណ្ណោះក្នុងចំណោមគោលនយោបាយទាំងប្រាំ - គោលនយោបាយផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយស្តីពីការកំណត់គោលដៅ- ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។ តាមវិធីនៃការដាក់កម្រិតបន្ថែមទៀតនោះ គោលនយោបាយផ្លាស់ទីលំនៅប្រជាជនត្រូវបានអនុវត្តតែទៅលើការផ្លាស់ប្តូរទីលំនៅប្រជាជន (ដំណាក់កាលទី I និងទី II តែប៉ុណ្ណោះ) ហើយគោលនយោបាយស្តីពីការកំណត់គោលដៅ ត្រូវបានអនុវត្តតែចំពោះទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[57]។ ឥឡូវវាបង្ហាញឲ្យឃើញ- ក្រោយពេលចេញសាលក្រម- ថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តការដាក់កម្រិតនេះចំពោះកថាខណ្ឌ ១៥២៥ នៃដីកាដំណោះស្រាយ ពួកគេបានពិចារណាថាខ្លួនបានដាក់ឧក្រិដ្ឋកម្មមួយចំនួន គឺឧក្រិដ្ឋកម្មបន្ថែម នៅខាងក្រៅវិសាលភាពនៃ JCE សម្រាប់គោលបំណងនៃសំណុំរឿង០០២/០១[58]។

24. ទោះជាយ៉ាងណា វាក៏ច្បាស់ផងដែរសម្រាប់ហេតុផលមួយចំនួនដែលថា ជនជាប់ចោទនៅតែទទួលបានការជូនដំណឹងនៅពេលនោះ (និងបានគូសបញ្ជាក់ខាងក្រោម បានប្រព្រឹត្តក្នុងលក្ខណៈមួយដែលស្របទៅនឹងការជូនដំណឹងនោះ) ថាពួកគេអាចត្រូវបានកាត់ឲ្យជាប់ទោសចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត ដោយផ្អែកលើ JCE។ ជាដំបូង ដោយការអានជំពូក៤ និង៥ នៃឧបសម្ព័ន្ធទាំង

[57] សូមមើល **E313** សាលក្រម កថាខណ្ឌ៧៨០-៨៧១ (បញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តតាមរយៈ JCE ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និងទី II) តែក្នុងបរិបទនៃការអនុវត្តគោលនយោបាយផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនតែប៉ុណ្ណោះ មិនមែនគោលនយោបាយស្តីពីការកំណត់គោលដៅ ដែលអនុវត្តតែចំពោះឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃប៉ុណ្ណោះ) និងកថាខណ្ឌ ៨១៣ (បញ្ជាក់ថា ទោះបីជា ទំនាក់ទំនងត្រូវបានបង្កើតឡើងនៅក្នុងដីកាដំណោះស្រាយរវាងទួលពោធិ៍ជ្រៃ និងគោលនយោបាយអប់រំកែប្រែ និងការសម្លាប់ខ្លាំងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាថាតើ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលបានកើតមាននៅទួលពោធិ៍ជ្រៃឬអត់ អនុលោមតាមគោលនយោបាយស្តីពីការកំណត់គោលដៅ)។ នៅក្នុង **E313** សាលក្រម ជើងទំព័រ ២៤៧២, ២៥៦២, អង្គជំនុំជម្រះសាលាដំបូងយោងសំអាង **E124/7.3** ឧបសម្ព័ន្ធ, ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២។ សូមមើលក្នុងផ្នែកនោះ **E124/7.3** ឧសបសម្ព័ន្ធ, ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ជំពូក១៖ "គោលនយោបាយដែលបានអនុវត្ត- ការផ្លាស់ទីលំនៅប្រជាជន (កថាខណ្ឌ១៦០-១៦៥) (កម្រិតត្រឹមការផ្លាស់ទីលំនៅ ប្រជាជនដំណាក់កាលទី១ និងទី២) និងវិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា (កថាខណ្ឌ២០៥-២០៩) (កម្រិតត្រឹមអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ)" និងជំពូកទី៥៖ "៥. ទម្រង់នៃការទទួលខុសត្រូវ (ក) សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ១៥២១-១៥២៥ (កថាខណ្ឌ១៥២៥ កចេញចំណុចលេខ (២) និង (៣), ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងចំណុចលេខ (៥))"។

[58] សូមមើល **E313** សាលក្រម កថាខណ្ឌ ៧៧៩-៧៧៨, ៨៨១-៨១៣, ៨៣៨, ៩៤៣។

មូល[59] បង្ហាញថាជនជាប់ចោទនៅតែចោទប្រកាន់ដោយបទឧក្រិដ្ឋ*ទាំងអស់*នៃសំណុំរឿង០០២/០១ ដោយរួមទាំងឧក្រិដ្ឋកម្មបន្ថែម អនុលោមតាម JCE។ ដោយពិចារណាលើកអង្គហេតុដែលថា ឧក្រិដ្ឋកម្ម*ទាំងអស់* ដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និងទី II) និង ទួលពោធិ៍ជ្រៃ ត្រូវបានចោទប្រកាន់អនុលោមតាម JCE នៅក្នុងដីកាដំណោះស្រាយ និងត្រូវបាន ចោទប្រកាន់ដោយផ្អែកលើទម្រង់ដទៃផ្សេងទៀតនៃការទទួលខុសត្រូវ នេះគឺជាការបកស្រាយសម ហេតុផលនៃឧបសម្ព័ន្ធនោះ។ គ្មានពេលណាមួយ នៅក្នុងសេចក្តីសម្រេច ឬក្នុងឧបសម្ពន្ធ ដែលអង្គ ជំនុំជម្រះបានបញ្ជាក់ច្បាស់ឡើយថា JCE មិនអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មបន្ថែម។

25. ទីពីរ ដូចបានកត់សម្គាល់ខាងលើ ដោយពិចារណាទៅលើទំនាក់ទំនងយ៉ាងច្បាស់លាស់ដែលបាន បង្កើតឡើងដោយ សចស រវាង ទួលពោធិ៍ជ្រៃ និងគោលនយោបាយអប់រំកែប្រែ និងសម្លាប់ខ្លាំង វា បង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានដាក់កម្រិតដោយមិនចាំបាច់ ក្នុងការការពិចារណាចំពោះ ការសម្លាប់នៅទួលពោធិ៍ជ្រៃចំពោះគោលនយោបាយស្តីពីការកំណត់គោលដៅ ស្តីពីការបំបែក សំណុំរឿង០០២/០១នោះ។ ប្រសិនបើអង្គជំនុំជម្រះបានដាក់បញ្ចូលគោលនយោបាយអប់រំកែប្រែ និងសម្លាប់ខ្លាំងនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១នោះ អង្គជំនុំជម្រះនឹងបានពិចារណា ចោទប្រកាន់ជនជាប់ចោទពីបទ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត *ការធ្វើទុកបុកម្នេញដោយ មូលហេតុនយោបាយ* អនុលោមតាម JCE ដោយសារតែពួកវាស្ថិតនៅក្នុងទម្រង់ផ្សេងទៀតនៃការ ទទួលខុសត្រូវ។ ស្រដៀងគ្នានេះដែរ ដូចបានគូសបញ្ជាក់ខាងលើការដាក់កម្រិតទាំងនោះ ត្រូវបាន ដាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៅដំណាក់កាលបំបែកសំណុំរឿង ដែលបានមើលរំលងទំនាក់ ទំនងដែលបានបង្កើតនៅក្នុងដីកាដំណោះស្រាយ រវាងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និងទី II) ហើយគោលនយោបាយស្តីពីការកំណត់គោលដៅ[60]។

---

[59] យោងតាម **E124/7.3** ឧបសម្ព័ន្ធ, ជំពូក៤, "ទាក់ទងនឹងបទល្មើសជាក់លាក់មួយចំនួន" រួមបញ្ចូលទាំងឧក្រិដ្ឋកម្មបន្ថែម។ សូមមើល "(ii) ការសម្លាប់រង្គាល (កថាខណ្ឌ១៣៨១-១៣៨៩ (កម្រិតត្រឹម*ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ទី២* និងទួលពោធិ៍ជ្រៃ)) (iii) ការធ្វើទុក្ខបុកម្នេញខាងនយោបាយ (កថាខណ្ឌ១៤១៥-១៤១៨, ១៤២៣-១៤២៥ (កម្រិតត្រឹម ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ និង*ទួលពោធិ៍ជ្រៃ*)) … (vi) ការបាត់ខ្លួនដោយបង្ខំ (កថាខណ្ឌ១៤៧០-១៤៧៨ (កម្រិតត្រឹម*ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២*))" (គូសបញ្ជាក់បន្ថែម)។ Moreover, Section 5(a) does not explain that the Targeting Policy does not apply to the Population Movements (Phases I and II)។

[60] សហព្រះរាជអាជ្ញាកត់សម្គាល់ចំពោះ **E313** សាលក្រម, កថាខណ្ឌ ៨១៣ ដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខ្លួនមិនត្រូវបានជាប់កាតព្វកិច្ចដោយការវិភាគអង្គហេតុរបស់ សចស នៅក្នុងដីកាដំណោះស្រាយ ដែលភ្ជាប់គោលនយោបាយ JCE ដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្មពាក់ព័ន្ធដែលបានចោទប្រកាន់ *យោង* **F28** សាលដីកា ឱុច កថាខណ្ឌ១២៨, ១៦៣។

26. លើសពីនេះ នៅមានការត្រួតជាន់លើគ្នារវាងគោលនយោបាយនានា ដែលការបកស្រាយមួយតូចចង្អៀតស្ដីពីការកម្រិតនានាដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានមើលរំលង[61]។ តាមពិត វាច្បាស់លាស់ហើយអំពីសេចក្ដីសម្រេចមួយចំនួន ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ដែលថាគ្រប់គោលនយោបាយទាំងប្រាំនេះ នៅតែមានការពាក់ព័ន្ធនៅឡើយ ហើយថាភាគីនានាត្រូវបានអនុញ្ញាតឲ្យនាំយកភស្តុតាងដែលទាក់ទងទៅនឹងពួកគាត់[62]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានពន្យល់ដូច្នោះដែរថា៖ "ដូច្នេះនឹងមិនមានការពិនិត្យលើការអនុវត្តគោលនយោបាយផ្សេងៗ ក្រៅពីគោលនយោបាយ *ដែលពាក់ព័ន្ធនឹង* ការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និងទី ២)"[63]។ (នៅពេលមានសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានដាក់បន្ថែមទួលពោធិ៍ជ្រៃទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១នៅឡើយទេ)។ ដោយហេតុថាឧក្រិដ្ឋកម្មអំពីការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ គឺជាផ្នែកនៃការអនុវត្តគោលនយោបាយទាំងឡាយ ដែលទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំជាជាង នៅក្នុងឧបសម្ព័ន្ធ នោះវាមានលក្ខណៈសមហេតុសមផលហើយសម្រាប់ឲ្យភាគីនានាជឿជាក់បានថា ដោយមិនគិតពីសេចក្ដីសម្រេចបំបែកដំណើរការនីតិវិធីជាទូទៅកំណត់វិសាលភាពសំណុំរឿង ០០២/០១ត្រឹមតែគោលនយោបាយពីរប៉ុណ្ណោះក្នុងចំណោម៥ ការចោទប្រកាន់ក្នុងដីកាដំណោះ

61 ដូចដែលអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ បានចង្អុលបង្ហាញនៅក្នុងសាលក្រមថា "ទាំងគោលនយោបាយ កំណត់គោលដៅ និង [គោលនយោបាយអប់រំកែប្រែ និងសម្លាប់ខ្មាំង] មានគោលបំណងរួមមួយដែលសំដៅទាំងការ "លុបបំបាត់ខ្មាំង" និងការ "សម្លាប់ខ្មាំង""។ សូមអាន **E313** សាលក្រម, កថាខណ្ឌ៨១៣។

62 សូមអាន **E141** ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និង ការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១, ១៧ វិច្ឆិកា ២០១១, ១៨ វិច្ឆិកា ២០១១ ("ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗរបស់ អជសដ"), ទំព័រ២។ **E313** សាលក្រម ជើងទំព័រ២៨៧។

63 **E141** ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗរបស់ អជសដ, ទំព័រ២។ ការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង "ការដាក់បញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការសម្លាប់ដែលត្រូវបានប្រព្រឹត្តនៅឯទួលពោធិ៍ជ្រៃ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់ណា ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ផ្ដល់ លទ្ធភាពឲ្យមានការពិនិត្យបានប្រធានបទចំនួនពីរ ក្នុងចំណោម*ប្រធានបទ* ចំនួនប្រាំសំខាន់ៗ នៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលរួមមាន ការជម្លៀសដោយបង្ខំ និង ការសម្លាប់ខ្មាំងនៃរបបនោះ [...] និងផ្ដល់លទ្ធភាពឲ្យសហព្រះរាជអាជ្ញាកដាក់បទល្មើសទាំងអស់នេះនៅក្នុងបរិបទទូលាយជាមុននៃសហឧក្រិដ្ឋកម្មរួម ដែលជនជាប់ចោទទាំងអស់ត្រូវបានចោទប្រកាន់ថាបានចូលរួម" ក៏មានលក្ខណៈស្របទៅនឹងទស្សនៈនេះផងដែរ។ សូមអាន **E284** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង០០២ តាមសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌ១១៨ (សង្កត់ន័យបន្ថែម)។

ស្រាយ ដែលថាឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទ គឺជាផ្នែកនៃ JCE ដែលនៅមានអានុភាព និងថា ទម្រង់នៃការទទួលខុសត្រូវនេះអនុវត្តទៅលើឧក្រិដ្ឋកម្មបន្ថែមផងដែរ ដែលជនជាប់ចោទនៅតែត្រូវបានចោទប្រកាន់ដោយឧក្រិដ្ឋកម្មទាំងនោះនៅឡើយ ដោយអនុលោមតាម JCE ដែលជាទម្រង់មួយនៃការទទួលខុសត្រូវ។

## គ. ជនជាប់ចោទ នឹងមិនមានការខូចចខាតដោយអយុត្តិធម៌អ្វីឡើយចំពោះការស្នើការកំណត់បទចោទប្រកាន់ជាថ្មី

27. តាមរយៈសារណាជាច្រើនដែលបានធ្វើដោយជនជាប់ចោទទាំងពីរ នៅក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានបំបែកសំណុំរឿង០០២ គេច្បាស់ណាស់ថា ជនជាប់ចោទម្នាក់ៗនៅតែជឿថា ខ្លួនត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងអស់នៃសំណុំរឿង០០២/០១ រួមទាំងឧក្រិដ្ឋកម្មបន្ថែមអនុលោមតាម JCE ឬ យ៉ាងហោចណាស់ បានដឹកនាំការការពារខ្លួនចំពោះបទចោទប្រកាន់ JCE ដែលនៅជាធរមាន ដោយពុំគិតដល់ឧក្រិដ្ឋកម្មជាមូលដ្ឋានដែលបានចោទប្រកាន់។

*នួន ជា*

28. នៅនៅក្នុងផ្នែកស្តីពីច្បាប់ជាធរមានទាក់ទងនឹង JCE នៃសារណារបស់គាត់ នួន ជា បានលើកឡើងយ៉ាងច្បាស់ថា ខណៈដែលគាត់បានដឹងថា "មានតែគោលនយោបាយពីរប៉ុណ្ណោះ ក្នុងចំណោមប្រាំ" ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ គឺគោលនយោបាយផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការប្រព្រឹត្តចំពោះក្រុមគោលដៅ"[64] គាត់បានពិចារណាខ្លួនឯងថាគាត់ "ត្រូវបានចោទប្រកាន់ពី (i) ការធ្វើមនុស្សឃាត, (ii) ការសម្លាប់រង្គាល (iii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង (iv) អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការផ្លាស់ទីលំនៅដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ" ទាក់ទិននឹងគោលនយោបាយទាំងនេះ[65]។ តាមរយៈការចង្អុលបង្ហាញខាងលើ វាច្បាស់លាស់ណាស់ថា ការ

---

[64] **E163/5/11** សារណាស្តីពីច្បាប់ជាធរមានរបស់ នួន ជា, កថាខណ្ឌ៣១ *លើកយោង* ឯកសារ **E124/7.3** ឧបសម្ព័ន្ធ, ៨ តុលា ២០១២, ERN: 00852356-00852358, ទំព័រ៣ (វាក្យខណ្ឌ ៥(ក))។

[65] **E163/5/11** សារណាស្តីពីច្បាប់ជាធរមានរបស់ នួន ជា, កថាខណ្ឌ៣១ *លើកយោង* ឯកសារ **E124/7.3** ឧបសម្ព័ន្ធ, ៨ តុលា ២០១២, ERN: 00852356-00852358, ទំព័រ២ (វាក្យខណ្ឌ ៤)។

លើកឡើងនេះ គឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មបន្ថែម[66]។គោលជំហរនេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងសារណាសវនាការនៃបណ្តឹងឧទ្ធរណ៍ ដែលនៅក្នុងនោះ នួន ជា បានធ្វើការអះអាងជាច្រើនដែលស្របទៅនឹងជំនឿថា គាត់ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មបន្ថែម[67] ដោយអនុលោមតាម JCE។

---

[66] វាក្យខណ្ឌ៤ដែល នួន ជា បានយោងនេះ ចែងនៅត្រង់ផ្នែកដែលពាក់ព័ន្ធថា "(ii) ការសម្លាប់រង្គាល (1381, 1387-1389 (កំហិតត្រឹម *ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី I និងទី II* និង ទួលពោធិ៍ជ្រៃ)) (iii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (1415-1418, 1423-1425 (កំហិតត្រឹម ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី I និងទី II និង *ទួលពោធិ៍ជ្រៃ*))... (iv) ការបាត់ខ្លួនដោយបង្ខំ (1470-1478 (កំហិតត្រឹម *ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី II*) (សង្កត់ន័យដើម)។ ជាងនេះទៀត ការលើកយោងការបាត់ខ្លួនដោយបង្ខំ ដែលត្រូវបានចោទប្រកាន់អនុលោមតាម JCE ចំពោះតែការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី II) ច្បាស់ណាស់ថា នួន ជា បានពិចារណាថាខ្លួនគាត់ត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មបន្ថែម។

[67] **<u>ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I)</u>៖ ការសម្លាប់រង្គាល៖ E295/6/3** សារណាសវនាការរបស់ នួន ជា, ចំណងជើង V.ឆ.ii, កថាខណ្ឌ៣១០ ("<u>ii - នួន ជា ពុំទទួលខុសត្រូវខាងព្រហ្មទណ្ឌតាមរយៈការចូលរួមនៅក្នុង JCE</u> ៣១០។ នួន ជា ពុំបានយល់ស្របជាមួយនឹងធាតុផ្សំ [...] នៃអំពើមនុស្សឃាត [...] ឡើយ។ នួន ជា ពុំមានចេតនាដូចបានតម្រូវចំពោះអំពើមនុស្សឃាត ... ឡើយ។ អាស្រ័យហេតុនេះ លោកមិនអាចរកឃើញពិរុទ្ធភាពតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមចំពោះអំពើណាមួយ ដែលអង្គជំនុំជម្រះកំណត់ថាបានកើតឡើងនៅក្នុងពេលជម្លៀសក្រុងភ្នំពេញឡើយ")។ **<u>ការផ្លាស់ទីលំនៅ ប្រជាជន (ដំណាក់កាលទី II)</u>៖ (i) ការសម្លាប់រង្គាល៖ E295/6/3** សារណាសវនាការរបស់ នួន ជា, ចំណងជើង VI.ក.ii, កថាខណ្ឌ៣៣២ ("<u>iii - គ្មានការឯកភាព គ្មានផែនការ គ្មានការបញ្ជា ឬការអុជអាលដើម្បីសម្លាប់រង្គាលឡើយ</u> ៣៣២។ សហ ព្រះរាជអាជ្ញាពុំបានបង្ហាញភ័ស្តុតាងថា នួន ជា បានចូលរួមនៅក្នុងគោលបំណងរួមមួយ ... ឲ្យបង្កើតស្ថានភាពរស់នៅ ដែលត្រូវ បានគិតថានាំទៅដល់ការសម្លាប់មនុស្សជាច្រើនឡើយ។ ដូចដែលកត់សម្គាល់រួចហើយ គ្មានឡើយភ័ស្តុតាងផ្ទាល់ដែលថាគណៈ កម្មាធិការអចិន្ត្រៃយ៍បានឯកភាព ... ដើម្បីផ្តួចផ្តើមការជម្លៀសប្រជាជនដែលត្រូវបានចោទប្រកាន់នេះ។ ជាចុងក្រោយ គ្មានឡើយភ័ស្តុតាងអំពីចេតនារបស់គណៈកម្មាធិការទាក់ទងនឹងស្ថានភាពនៃការជម្លៀស និងការស្លាប់ទ្រង់ទ្រាយធំរបស់ប្រជាជន ជម្លៀសដែលត្រូវបានចោទប្រកាន់នោះ")។ សូមអានផងដែរ **E1/233.1** សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា, ប្រតិចារឹក ២៤ តុលា ២០១៣, ទំព័រ៩០ ("ដោយសារគ្មានភស្តុតាងដោយផ្ទាល់ក្នុងការរកឲ្យឃើញពីការស្លាប់ដ៏ច្រើន ពាក់ព័ន្ធ ការជម្លៀសដំណាក់កាលទីពីរ វាមិនអាចសន្និដ្ឋានថាបទល្មើសនេះកើតឡើង បើទោះជាគោលនយោបាយ ឬវចនាសម្ព័ន្ធរបស់ គណបក្ស -- បក្សកម្ពុជាក្នុងការសម្លាប់ជនភៀសខ្លួន")។ ៩១ (ដោយការយោងទៅដល់ការសម្លាប់រង្គាលនៅក្នុងអំឡុងពេលនៃ ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ "គ្មានភស្តុតាងបង្ហាញថាលោក នួន ជា ឬគណៈអចិន្ត្រៃយ៍ចូលរួមក្នុងគោលបំណង រៀបចំគម្រោងចេញបញ្ជា ឬក៏ជំរុញឲ្យបុគ្គលណាមួយបង្កឲ្យមានលក្ខណៈនានាដែលនាំទៅរកសេចក្តីស្លាប់របស់ប្រជាជនក្នុង ទ្រង់ទ្រាយធំនោះដែរ។ លោក នួន ជា គ្មានជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់នេះទេ")។ **(ii) ការបាត់ខ្លួនដោយបង្ខំ៖ E295/6/3** សារណាសវនាការរបស់ នួន ជា, កថាខណ្ឌ៣៥៨ (ដោយមានចំណងជើង) ("iii - គ្មានកិច្ចព្រមព្រៀង គ្មានផែនការ គ្មានបទ បញ្ជា គ្មានការញុះញង់ ឬការលើកទឹកចិត្ត ៣៥៨។ [...] គ្មានភ័ស្តុតាងអំពីធាតុផ្សំជាក់ស្តែងនៃការទទួលខុសត្រូវជាលក្ខណៈ បុគ្គលរបស់ នួន ជា ចំពោះការបាត់ខ្លួនដោយបង្ខំតាមរយៈទម្រង់ណាមួយនៃការប្រព្រឹត្តិឡើយ។ គ្មានឡើយភ័ស្តុតាងផ្ទាល់អំពីការបង្គាប់ ឬការឯកភាព

29. ជាងនេះទៀត អំណះអំណាងជាច្រើនដែលដំណើរការដោយ នួន ជា នោះ អាចត្រូវបានយកទៅអនុវត្តបានជាទូទៅចំពោះរាល់ឧក្រិដ្ឋកម្មទាំងអស់។ ឧទាហរណ៍ នួន ជា បានអះអាងក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I) ថារូបគាត់មិនបាន "បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមជាមួយ [...] ចារីដែលបានប្រព្រឹតឧក្រិដ្ឋកម្មទាំងនេះឡើយ ពីព្រោះ [...] ចារីទាំងនេះជាអ្នកប្រព្រឹត្តដោយចិត្តឯង ឬស្ថិតនៅក្រោមការបញ្ជារបស់មេដឹកនាំតាមភូមិភាគហួសពីការគ្រប់គ្រងរបស់ នួន ជា"[68]។ គាត់បានធ្វើការអះអាងស្រដៀងគ្នានេះដែរទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាល់ទី II)[69] និងទួលពោធិ៍ជ្រៃ[70]។

30. ក្នុងគ្រប់អង្គហេតុទាំងអស់ នួន ជា បានការពាររាល់ធាតុសត្យានុម័តនៃ JCE ទាក់ទងនឹងឧក្រិដ្ឋកម្មនីមួយៗនៃឧក្រិដ្ឋកម្មបន្ថែមទាំងអស់នេះ។ ទាក់ទងនឹងឧក្រិដ្ឋកម្មបន្ថែមនីមួយៗ គាត់បានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងច្បាប់ជាធរមាន នៃឧក្រិដ្ឋកម្មជាមូលដ្ឋាននីមួយៗ[71] ហើយបានតវ៉ាជំទាស់ទៅនឹងមូលដ្ឋានឧក្រិដ្ឋកម្មផ្នែកអង្គហេតុ[72]។ ជាពិសេសនោះពាក់ព័ន្ធនឹងការទទួលខុសត្រូវ JCE

---

ចេញពីមជ្ឈិមបក្ស ឬភ័ស្តុតាងអំពីលំនាំនៃទង្វើដែលបង្ហាញអំពីគោលនយោបាយនេះ")។ សូមអាន ផងដែរ **E1/233.1** សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា, ប្រតិចារឹក ២៤ តុលា ២០១៣, ទំព័រ១០០ ("គ្មាន ភស្តុតាងណាមួយអាចបញ្ជាក់ពីធាតុផ្សំនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ចំពោះការបាត់ខ្លួនដោយបង្ខំតាមរយៈការ ប្រព្រឹត្តណាមួយក៏ដោយ")។ **<u>ទួលពោធិ៍ជ្រៃ</u>៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** **E295/6/3** សារណាសវនាការ របស់ នួន ជា, ចំណងជើង VII C., VII C.ii. និងកថាខណ្ឌ ៤១៦-៤១៧ ("**គ. នួន ជា ពុំមានពិរុទ្ធភាពឡើយចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ដោយសារតែការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋរួម (JCE) [...]** <u>ii នួន ជា មិនបានយល់ព្រមឡើយក្នុងការសម្លាប់អ្នករដ្ឋការ ឬទាហាន លន់ នល់</u> [...] ៤១៦. [...] អង្គហេតុទាំងនេះតែមួយមុខគឺគ្រប់គ្រាន់ដើម្បីឲ្យ នួន ជា រួចខ្លួនពីការចោទប្រកាន់អំពីការទទួលខុសត្រូវតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ។ ៤១៧. [...] គ្មានភ័ស្តុតាងបង្ហាញថាមានការពិភាក្សាអំពីការ ធ្វើទុក្ខបុកម្នេញលើអ្នករដ្ឋការ លន់ នល់ ឡើយ ចុះទម្រាំការសម្លាប់ទៀតនោះ")។

68 **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៣០៥។ ចំពោះការពន្យល់នៃអំណះអំណាងនេះ សូមមើល **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៣០៦-៣០៩ និង៣១១-៣១២។

69 **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៣១៨-៣១៩។

70 **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៤០៣, ៤០៧, ៤១៣។

71 **<u>ការសម្លាប់រង្គាល</u>៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ២១៥-២១៩។ **<u>ការបាត់ខ្លួនដោយបង្ខំ៖</u>** **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ២២៧-២២៩។ **<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖</u>** **E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ២២០-២២៦។

72 **<u>ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទីI)</u>៖ ការសម្លាប់រង្គាល៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ២៣៤, ២៥៩-២៦៨។ **<u>ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី II)</u> (i) ការសម្លាប់រង្គាល៖**

ចំពោះឧក្រិដ្ឋកម្មបន្ថែមទាំងអស់នេះ គាត់បានអះអាងថាគាត់គឺជាភាគីមិនឯកភាព មិនមានផែនការ ឬគោលបំណងរួមដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងអស់នេះទេ[73] និងថា គាត់ក៏មិនមសនចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះនោះទេ[74]។

### *ខៀវ សំផន*

31. ដោយទទួលបានឱកាសដើម្បីបង្ហាញការការពារខ្លួនចំពោះការអនុវត្តការទទួលខុសត្រូវតាមទម្រង់ JCE នោះ ខៀវ សំផន បានធ្វើការការពារខ្លួន ដែលមិនខុសប្លែកគ្នារវាងឧក្រិដ្ឋកម្មជាមូលដ្ឋាន ដែលត្រូវបានចោទប្រកាន់នោះទេ។ ដូច្នេះ ការការពារក្តីនោះមិនមែនផ្អែកលើថាតើ គាត់ត្រូវបាន ចោទប្រកាន់ដោយឧក្រិដ្ឋកម្មបន្ថែមតាមទម្រង់ JCE ឬអត់នោះឡើយ។ ខៀវ សំផន បានបដិសេធ ការចូលរួមណាមួយក្នុងឧក្រិដ្ឋកម្ម និងបានតវ៉ាទៅនឹងការចោទប្រកាន់*ជារួម* ដែលផ្តោតទៅលើក ង្វះខាតអំណាចក្នុងការធ្វើការសម្រេចចិត្តណាមួយរបស់គាត់។ នៅក្នុងសេចក្តីសន្និដ្ឋានជា លាយលក្ខណ៍អក្សរ ដែលលើកឡើងយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវតាមទម្រង់ JCE ខៀវ សំផន បានអះអាងនៅក្នុងសវនាការថា៖

---

**E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ៣២១-៣២៨។ **(ii) ការបាត់ខ្លួនដោយបង្ខំ៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ៣៥៣-៣៥៦, ៣៥៩។ **ទួលពោធិ៍ជ្រៃ៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ ៤២២-៤២៦ ។

[73] សូមមើល យោងខាងលើ ជើងទំព័រ៦៧។

[74] **<u>ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី I)</u>៖ ការសម្លាប់រង្គាល៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ២៣៤, ២៦២-២៦៨។ **<u>ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី II)</u>: (i) ការសម្លាប់រង្គាល៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៣២៨-៣៣១។ **(ii) ការបាត់ខ្លួនដោយបង្ខំ៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៣៥៧។ **<u>ទួលពោធិ៍ជ្រៃ</u>៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ E295/6/3** សារណាសវនាការរបស់ នួន ជា កថាខណ្ឌ៤១៤, ៤៤២ [ទាក់ទងនឹង ទួលពោធិ៍ជ្រៃ គាត់តវ៉ាថាមិនមានគោលនយោបាយ សម្លាប់អតីតមន្ត្រីរដ្ឋការ និងទាហានរបប លន់ នល់ ឡើយ - អំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅទីនោះ។ សេចក្តីសន្និដ្ឋានទាក់ទងនឹងចេតនាជាក់លាក់របស់ នួន ជា ក្នុងការរើសអើងប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការរបប លន់ នល់ ក្នុងខែមេសា ឆ្នាំ១៩៧៥ ក៏ពាក់ព័ន្ធនឹងបរិបទនៃការផ្លាស់ទីលំនៅដោយបង្ខំដំណាក់កាលទីមួយផងដែរ។] សូមមើលផងដែរ **E1/232.1** សេចក្តីថ្លែងបិទរបស់ នួន ជា, ប្រតិចារឹក ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ទំព័រ៣៨ ("ទាក់ទងនឹង ទួលពោធិ៍ជ្រៃ ហេង សំរិន គឺជាសាក្សីដែលត្រូវបានគេស្គាល់តែម្នាក់គត់ ដែលមានភស្តុតាងផ្ទាល់នៃចេតនារបស់កូនក្តីយើង ចំពោះការប្រព្រឹត្តលើទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ [...] គាត់បានប្រាប់លោក Ben Kiernan ថា កូនក្តីរបស់យើងបានណែនាំយ៉ាងជាក់លាក់ឲ្យមិនកម្មាភិបាលសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរឡើយ")។

ក. គាត់មិនមានអំណាចពិតប្រាកដនៅក្នុងស្ថាប័នរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីធ្វើការសម្រេចចិត្តទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ឬវិធានការឧក្រិដ្ឋប្រឆាំងនឹងមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរនោះទេ និងមិនបានចូលរួមចំណែកក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់កម្មាភិបាលថ្នាក់ក្រោមឡើយ[75]។

ខ. វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគឺអកម្មតែប៉ុណ្ណោះ និងមិនដែលមានទំនាក់ទំនងទៅនឹងសហឧក្រិដ្ឋកម្មឡើយ[76]។

គ. ការខកខានក្នុងការរារាំង ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មណាមួយ មិនពាក់ព័ន្ធនឹងការ ទទួលខុសត្រូវ នៅក្រោម JCE នោះទេ[77]។

ឃ. គាត់មិនមានចេតនាឧក្រិដ្ឋ ដែលជាធាតុសំខាន់នៃ JCE នោះទេ ដោយហេតុថាការគាំទ្រខាងបញ្ញាស្មារតីរបស់គាត់ចំពោះ "គោលបំណងចុងក្រោយ" នៃការប្រព្រឹត្តបទល្មើស មិន គ្រប់គ្រាន់ទ[78]ក្នុងការវាយតម្លៃថាគាត់បានចូលរួមប្រព្រឹត្តបទឧក្រិដ្ឋតាម JCE។ មានតែវិភាគទានសំខាន់ចំពោះមធ្យោបាយនានាដែលបានប្រើប្រាស់ដើម្បី ធានានូវ "គោលបំណងចុងក្រោយ"

---

75 **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន កថាខណ្ឌ៣១៦៖ «KHIEU Samphân n'était pas en position de pouvoir réel au sein des organes du KD qui ont pris la décision des déplacements de population ou de prétendues mesures criminelles à l'encontre des ex-RK. Ses fonctions au sein du KD n'ont pas non plus contribué aux agissements criminels des cadres locaux dans les régions à l'arrivée des déplacés. »

76 **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន កថាខណ្ឌ ៣១៧៖ «Par ailleurs, les documents relatifs aux réunions auxquelles il aurait assisté démontrent que sa présence y était passive et toujours en lien avec des rôles sans rapport avec un projet criminel.»

77 **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ៣១៣៖ "Il est également important de préciser que le fait de ne pas empêcher ou punir un crime ne permet pas d'engager la responsabilité d'un accusé au titre de l'ECC" (*Le Procureur* c. *Mpambara,* Affaire. សំណុំរឿងលេខ ICTR-01-65-T, សាលក្រម, ១២ កញ្ញា ២០០៦, កថាខណ្ឌ៣៩)។

78 **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ៣១៣៖ "Or, comme la Défense l'a développé dans le cadre de son mémoire sur le droit applicable et conformément à la jurisprudence internationale:" (…) *il existe clairement une distinction entre « l'objectif ultime» et le but criminel commun à proprement parler. Ce n'est pas l'adhésion intellectuelle au but ultime qui permet de déduire l'intention criminelle du participant à l'ECC mais une participation significative aux moyens criminels utilisés pour y parvenir"»* «Dans le cadre, du procès 002/01, il n'a pas été prouvé en quoi KHIEU Samphân aurait participé de façon significative aux moyens criminels utilisés dans le cadre de la politique des déplacements de la population et en quoi KHIEU Samphân aurait participé de façon significative aux événements de Tuol Po Chrey.»។

ប៉ុណ្ណោះ ដែលគាត់បានអះអាងថាគាត់មិនត្រូវបានគេឲ្យធ្វើការបកស្រាយបង្ហាញ[79] ដែលត្រូវតាមលក្ខខណ្ឌតម្រូវនានាខាងផ្លូវច្បាប់ សម្រាប់ JCE។

ង. ពុំមានអ្វីនៅក្នុងអាកប្បកិរិយា ឬតួនាទីរបស់គាត់ ដូចអ្វីដែលសាក្សីនានាបានរៀបរាប់ នោះអនុញ្ញាតឲ្យមានជាសេចក្តីសន្និដ្ឋានថា គាត់បានដឹងឮពីឧក្រិដ្ឋកម្មនានា ឬមានចេតនាជំរុញឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និងទី II) ឬ នៅទួលពោធិ៍ជ្រៃ នោះឡើយ[80]។

32. ដោយត្រូវបានចោទប្រកាន់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដទៃទៀត តាមរយៈការចូលរួមប្រព្រឹត្តនៅក្នុង JCE ព្រមទាំងឧក្រិដ្ឋកម្មបន្ថែមនិមួយៗដែលស្ថិតក្រោមទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត ខៀវ សំផន មានឱកាសបង្ហាញ និងបានធ្វើការបង្ហាញសេចក្តីសន្និដ្ឋានផ្សេងៗ ទាក់ទងនឹងច្បាប់ជាធរមាន និងមូលដ្ឋានអង្គហេតុឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្មជាមូលដ្ឋាន។ គាត់បានបង្ហាញសេចក្តីសន្និដ្ឋានស្តីពីច្បាប់ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌

[79] ដោយឡែក ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ខៀវ សំផន បានជជែកអះអាងថា សុន្ទរកថានានារបស់គាត់ទាក់ទង នឹងការជម្លៀសដោយបង្ខំ គឺបានពិភាក្សាតែពីគោលនយោបាយសេដ្ឋកិច្ចប៉ុណ្ណោះ ហើយថាសកម្មភាពនានារបស់គាត់ ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការចែកចាយសម្ភារៈផ្គត់ផ្គង់មូលដ្ឋាន គឺបានបង្ហាញពីបំណងរបស់គាត់ក្នុងការជួយដល់ ប្រជាជន មិនមែនជាវិភាគទានរបស់គាត់ចំពោះឧក្រិដ្ឋកម្មនានា នោះទេ។ សូមអាន **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ៣១៣៖ "Sur les déplacements de population, les discours qu'il aurait prononcés comme Vice-Premier ministre ou président du Présidium évoquent uniquement la politique économique socialiste prônée par les KR. Par ailleurs, ses activités en relation avec le commerce et dans le cadre de la distribution de matériel dans les zones, loin de démontrer une contribution aux crimes, manifestent au contraire une volonté d'assistance à la population."។ ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ខៀវ សំផន គ្រាន់តែជជែកអះអាងថា ពុំមានអ្វីជាប់ទាក់ទងនឹងគាត់ទេ ចំពោះទីតាំងនោះ - គឺគាត់មិនមានជាប់ទាក់ទងអ្វីជាមួយនឹងកាតព្វកិច្ច នៅខែមេសា ឆ្នាំ១៩៧៥ ហើយសុន្ទរកថានានារបស់គាត់ដែលបានធ្វើឡើងនៅក្នុងសម័យសង្គ្រាមនោះ ក៏ទេដែរ។ សូមអាន **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ៣១៤៖ "Sur les événements de Tuol Po Chrey, rien ne permet de relier KHIEU Samphân au site de Tuol Po Chrey, ni dans le cadre de ses fonctions en avril 1975, ni dans les discours préalables prononcés en temps de guerre."។

[80] **E295/6/4** សារណាសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ៣១៧៖ "Enfin, rien dans son comportement ni dans son rôle tel qu'il a été décrit par les différents témoins ne permet de conclure qu'il était au courant de la commission de crimes ou avait l'intention d'encourager la commission de crimes à l'encontre de la population, que ce soit lors des 1er et 2ème déplacements ou au moment des faits prétendument commis en avril 1975 à Tuol Po Chrey."។

ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ[81] និងការកកើតនៃទីតាំងសម្លាប់មនុស្សនៅ ទួលពោធិ៍ជ្រៃ[82]។ ជាការបន្ថែម គាត់បានធ្វើសេចក្តីសន្និដ្ឋានយ៉ាងទូលំទូលាយទាក់ទងនឹងការរួម ចំណែករបស់គាត់ទៅក្នុងការផ្លាស់ទីលំនៅប្រជាជន[83] និងគោលនយោបាយដែលនាំឱ្យមានការវាយប្រហារទៅលើអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋ[84]។ ដោយសង្ខេប គាត់ត្រូវបានផ្តល់ឱ្យនូវឱកាសគ្រប់បែបយ៉ាង ដើម្បីការពារខ្លួនគាត់ពីទម្រង់នៃការទទួលខុសត្រូវ JCE និងឧក្រិដ្ឋកម្មបន្ថែម ហើយគាត់ពិតជាបានប្រើប្រាស់ឱកាសទាំងនោះ។

## I. សេចក្តីសន្និដ្ឋាន

33. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ប្រសិនបើ អជតក ជឿជាក់លើមូលដ្ឋាននៃការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ឬលើភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែលបានបង្កើតឡើងហួសពីវិមតិសង្ស័យថា នួន ជា និង ខៀវ សំផន បានចូលរួមប្រព្រឹត្តនៅក្នុង JCE ទាក់ទងនឹងឧក្រិដ្ឋកម្មបន្ថែម នោះអង្គជំនុំជម្រះអាចធ្វើការកំណត់បទចោទឡើងវិញចំពោះការកាត់ទោសនានា ស្របតាមវិធាន១១០ នៃវិធានផ្ទៃក្នុង សម្រាប់ឧក្រិដ្ឋកម្មបន្ថែម និងបញ្ចូលការកាត់ទោសនៅក្រោម JCE ប្រឆាំងនឹងជនជាប់ចោទទាំងពីរ។

---

81 **<u>ការបាត់ខ្លួនដោយបង្ខំ</u>:** **E163/5/9** សេចក្តីសន្និដ្ឋានស្តីពីច្បាប់ជាធរមានរបស់ ខៀវ សំផន, កថាខណ្ឌ៩, ២៩-៣២។ **<u>ការធ្វើទុក្ខ បុកម្នេញដោយមូលហេតុនយោបាយ</u>:** **E163/5/9** សេចក្តីសន្និដ្ឋានស្តីពីច្បាប់ជាធរមានរបស់ ខៀវ សំផន, កថាខណ្ឌ ៤, ២៤-២៦។

82 **E295/6/4** សារណាសរនាការរបស់ ខៀវ សំផន, កថាខណ្ឌ៨១-៩៣។

83 **<u>ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I)</u>:** **E295/6/4** សារណាសរនាការរបស់ ខៀវ សំផន, កថាខណ្ឌ២៨៧-២៩៦។ **<u>ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី II)</u>:** **E295/6/4** សារណាសរនាការរបស់ ខៀវ សំផន, កថាខណ្ឌ២៩៧-៣០០។

84 **E295/6/4** សារណាសរនាការរបស់ ខៀវ សំផន, កថាខណ្ឌ៣០១-៣០៦។

34. អង្គជំនុំជម្រះក៏មានឆន្ទានុសិទ្ធិក្នុងការកំណត់បទចោទឡើងវិញ ដោយអនុលោមតាមវិធាន១១០ នៃវិធានផ្ទៃក្នុងចំពោះឧក្រិដ្ឋកម្ម JCE ព្រមទាំងធ្វើការកាត់ទោសនៅក្រោមទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត។ ការកំណត់បទចោទឡើងវិញក៏មិនរំលោភសិទ្ធិរបស់ជនជាប់ចោទនោះដែរ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |